ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៥១៣ /២២-៥-២០០៧

សាលដីកា

លេខ : ៧០"ជ"/០១-៩-២០១០

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យ លេខ០៦ក្រ ចុះថ្ងៃទី ០៨ កុម្ភៈ ១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ កាលពីថ្ងៃទី ០១-៩-២០១០ ដែលមានសមាសភាពដូចខាងក្រោមនេះ

**ក្រុមប្រឹក្សាជំនុំជំរះ**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រម

លោក [redacted] ជាចៅក្រម

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

លោកស្រី [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ : ៥១៣ ចុះថ្ងៃទី ២២-៥-២០០៧ រវាង :

១- ជនជាប់ចោទឈ្មោះ [redacted] **ចាន់ធឿន** " ដើមបណ្តឹងឧទ្ធរណ៍ " ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ កើតនៅ [redacted] ករិតវប្បធម៌គ្មាន សាសនាព្រះពុទ្ធ មានទីលំនៅ [redacted] របររកស៊ីរត់ម៉ូតូឌុប នៅលីវ ។ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "ស" ។

- ត្រូវជាប់ចោទពីបទ : **ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា** ប្រព្រឹត្តនៅ ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ កាលពីថ្ងៃទី ០៥-៩-២០០៥ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងអោយ ផ្តន្ទាទោសតាមមាត្រា ០៤ នៃច្បាប់ស្តីពី ស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ ។

២- ជនជាប់ចោទឈ្មោះ [redacted] **ឡៃន** " ដើមបណ្តឹងឧទ្ធរណ៍ " ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ កើតនៅ [redacted] សាសនាព្រះពុទ្ធ មានទីលំនៅ [redacted] មុខរបររកស៊ីកម្មករសំណង់ ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុនគ្មាន ។

- ត្រូវជាប់ចោទពីបទ : **ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា** ប្រព្រឹត្តនៅ ភូមិដំណាក់ធំ សង្កាត់ស្ទឹងមាន

ជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ កាលពីថ្ងៃទី ០៥-៩-២០០៥ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងអោយ ផ្តន្ទាទោសតាមមាត្រា ០៤ នៃច្បាប់ស្តីពី ស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ ។

៣~ ជនជាប់ចោទឈ្មោះ [redacted] វណ្ណ " ដើមបណ្តឹងឧទ្ធរណ៍ " ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ កើតនៅ [redacted] សាសនាព្រះពុទ្ធ មានទីលំនៅ [redacted] មុខរបររកស៊ីកម្មករ ប្រពន្ធឈ្មោះ [redacted] កូនគ្មាន ។ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុនគ្មាន ។

- ត្រូវជាប់ចោទពីបទ : **ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា** ប្រព្រឹត្តនៅ ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ កាលពីថ្ងៃទី ០៥-៩-២០០៥ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងអោយ ផ្តន្ទាទោសតាមមាត្រា ០៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ ។

៤~ ជនជាប់ចោទឈ្មោះ [redacted] **ឈូក** " ដើមបណ្តឹងឧទ្ធរណ៍ " ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ កើតនៅ [redacted] សាសនាព្រះពុទ្ធ មានទីលំនៅផ្ទះ [redacted] មុខរបររកស៊ីកម្មករ ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] " ម្តាយឈ្មោះ [redacted] " រ " ទោសពីមុនគ្មាន ។

- ត្រូវជាប់ចោទពីបទ : **ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា** ប្រព្រឹត្តនៅ ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ កាលពីថ្ងៃទី ០៥-៩-២០០៥ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងអោយ ផ្តន្ទាទោសតាមមាត្រា ០៤ នៃច្បាប់ស្តីពី ស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ ។

**ឯរឿងហេតុមានដូចតទៅ :**

កាលពីថ្ងៃទី ០៥-៩-២០០៥ វេលាម៉ោងប្រហែល ១៩:៥០នាទី ឈ្មោះ [redacted] វណ្ណ ភេទប្រុស អាយុ ១៩ឆ្នាំ ឈ្មោះ [redacted] **ឈូក** ភេទប្រុស អាយុ ១៩ឆ្នាំ, ឈ្មោះ [redacted] **ចាន់ធឿន** ភេទប្រុស អាយុ ១៩ឆ្នាំ និងឈ្មោះ [redacted] **ខ្សែ**រ ភេទប្រុស អាយុ ២២ឆ្នាំ បានធ្វើសកម្មភាព **ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា** ទៅលើជនរងគ្រោះ ដោយមុនពេលកើតហេតុ កំលាំងល្បាតនគរបាលប៉ុស្តិ៍ស្ទឹងមានជ័យ ល្បាតតាមដងផ្លូវស្ទឹងមានជ័យ ដល់ចំណុចភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ក៏បានជួបប្រទះក្រុមបងធំខាងលើ សុទ្ធតែកាន់ដាវកាំបិត ដំបង គ្រប់ដៃក៏បានឃាត់ខ្លួនជនល្មើសខាងលើ និងវត្ថុតាងតែម្តង ។

- **បានឃើញសាលក្រមព្រហ្មទណ្ឌលេខ : ២៤ "ឃ" ចុះថ្ងៃទី ២៥-១០-២០០៦ របស់សាលាដំបូងក្រុងភ្នំពេញ ដែលមានខ្លឹមសារដូចតទៅ :**

១- ផ្តន្ទាទោស ឈ្មោះ [redacted] វណ្ណ ភេទប្រុស អាយុ ១៩ឆ្នាំ, ឈ្មោះ [redacted] **ឈូក** ភេទប្រុស អាយុ ១៩ឆ្នាំ, ឈ្មោះ [redacted] **ចាន់ធឿន** ភេទប្រុស អាយុ ១៩ឆ្នាំ និងឈ្មោះ [redacted] **ខ្សែន** ភេទប្រុស អាយុ ២២ឆ្នាំ ដាក់ពន្ធនាគារ ត្រូវអោយធ្វើការក្នុងម្នាក់ៗ កំណត់ ១០ឆ្នាំ គិតពីថ្ងៃ ឃុំខ្លួន ០៦-៩-០៥ ។

ពីបទ : **ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា** ប្រព្រឹត្តនៅខណ្ឌមានជ័យ ក្រុងភ្នំពេញ កាលពីថ្ងៃទី ០៥-៩-២០០៥ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ០៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ ។

១៤០

២- វត្ថុតាង មានដាវដែក ប្រហែល មួយម៉ែត្រ ចំនួនមួយត្រូវរឹបអូស បំផ្លាញចោល ។

៣- សាលក្រមនេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ បើកផ្លូវប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

- បានឃើញសេចក្តីសុំប្តឹងតវ៉ា ចុះថ្ងៃទី ២១-១១-២០០៦ របស់ជនជាប់ចោទ ឈ្មោះ [redacted] ឈូក និង ឈ្មោះ [redacted] ចាន់ធឿន (ពាក្យបណ្តឹងថ្ងៃទី ២០-១១-២០០៦ ) ប្តឹងឧទ្ធរណ៍ និងសាលក្រមព្រហ្មទណ្ឌលេខ ២៤ "ឃ" ចុះថ្ងៃទី ២-១០-២០០៦ ត្រង់សេចក្តីសំរេចសាលក្រមទាំងមូល ។ ( ឯកសារ ៥១. ៥២ )

- បានឃើញសេចក្តីសុំប្តឹងតវ៉ា ចុះថ្ងៃទី ៣០-១១-២០០៦ របស់ជនជាប់ចោទ ឈ្មោះ [redacted] ខ្សែន និង ឈ្មោះ [redacted] វណ្ណ ប្តឹងឧទ្ធរណ៍ និងសាលក្រមព្រហ្មទណ្ឌលេខ ២៤ "ឃ" ចុះថ្ងៃទី ២៥-១០ ២០០៦ ត្រង់សេចក្តីសំរេច សាលក្រមទាំងមូល ។ ( ពាក្យបណ្តឹងថ្ងៃទី ២៩-១១-២០០៦) ( ឯកសារ ៤. .៥០ ) ។

- បានឃើញសេចក្តីសន្និដ្ឋាន ចុះថ្ងៃទី ១១-៧-០៨ របស់មហាអយ្យការអមសាលាឧទ្ធរណ៍ ។

- បានឃើញរបាយការណ៍ ចុះថ្ងៃទី ២៥-៦-០៩ របស់ចៅក្រមសាលាឧទ្ធរណ៍ ។

## នារពេលសវនាការ

- ជនជាប់ចោទ ឈ្មោះ [redacted] វណ្ណ "អវត្តមាន"
- ជនជាប់ចោទ ឈ្មោះ [redacted] ឈូក "អវត្តមាន"
- ជនជាប់ចោទ ឈ្មោះ [redacted] ចាន់ធឿន "អវត្តមាន"
- ជនជាប់ចោទ ឈ្មោះ [redacted] ខ្សែន "អវត្តមាន"
- មេធាវីលោក [redacted] ចន្ធា ការពារឱ្យជនជាប់ចោទ " វត្តមាន "

- ប្រធានក្រុមប្រឹក្សា ធ្វើការអធិប្បាយហេតុការណ៍ នៃរឿងដែលកើតមានឡើង និងអានសេចក្តីសំរេចរបស់សាលាដំបូងក្រុងភ្នំពេញ ។

- **តំណាងមហាអយ្យការផ្តល់សេចក្តីសន្និដ្ឋាន** : គ្មានភស្តុតាង និងគ្មានពិរុទ្ធភាពគ្រប់គ្រាន់លើ ឈ្មោះ [redacted] ចាន់ធឿន . [redacted] វណ្ណ . [redacted] ឈូក . [redacted] ខ្សែន ពីបទ : **ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា** ដោយមាន លក្ខណៈមិនគ្រប់គ្រាន់ តាមធាតុផ្សំនៃបទល្មើស ខ្វះធាតុផ្សំបទល្មើស និងគ្មានព្យាសនកម្ម គ្មានជនរងគ្រោះ ។

គប្បីប្រធានក្រុមប្រឹក្សាជំនុំជំរះ លើកយកមកពិចារណាក្នុងការសំរេច ។

- **មេធាវីធ្វើសេចក្តីសន្និដ្ឋាន** : ក្នុងរឿងនេះ ខ្ញុំសូមឯកភាពទៅលើការសន្និដ្ឋានរបស់លោកតំណាងមហាអយ្យការ ។ អំពើត្រៀមបំរុង ពុំមែនជាបទល្មើសទេ គ្រាន់តែមានការសង្ស័យទៅលើកូនក្តីខ្ញុំ ។

**សំណូមពរ :** សូមប្រធានក្រុមប្រឹក្សា និងក្រុមប្រឹក្សា មេត្តាឱ្យកូនក្តីខ្ញុំបានរួចផុតពីការចោទប្រកាន់ ។

- ក្រោយពីបានអាន ចម្លើយជនជាប់ចោទ ។
- ក្រោយពីបានអាន ចម្លើយដើមបណ្តឹង ។
- ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន ។

១៤១

- ក្រោយពីបានស្តាប់មេធាវីធ្វើសេចក្តីសន្និដ្ឋាន ។
- ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធល្អិតល្អន់ ។
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ ។

**សាលាឧទ្ធរណ៍**

- យល់ឃើញថា :

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃ ៣០-១១-២០០៦ របស់ជនជាប់ចោទ ឈ្មោះ [redacted] **ខ្សៀន** និង [redacted] **វណ្ណ** និ បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃ ២១-១១-២០០៦ របស់ឈ្មោះ [redacted] **ឈូក** ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រ ១៧៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៦០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍ ទទួលជំនុំជំៈ បាន ។

២- មេធាវី [redacted] **ចន្ថា** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៣- តាមរបាយការណ៍ ប៉ុស្តិ៍នគរបាលរដ្ឋបាលស្ទឹងមានជ័យ ចុះថ្ងៃ ៦ កញ្ញា ២០០៥ បញ្ជាក់ថា នៅថ្ងៃ ៥ កញ្ញា ២០០៥ ម៉ោង ១៩ម៉ ៥០នាទី នៅមុខផ្ទះសំណាក់មានជ័យ ផ្លូវចោមចៅ ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័ កំលាំងល្បាតរបស់ប៉ុស្តិ៍បានឃើញ ក្រុមបងធំ ៤នាក់ ខ្លះកាន់កាំបិត ដាវ និងដំបង មានឈ្មោះ [redacted] **វណ្ណ** ហៅ **ខ្ទាន់** [redacted] **ចាន់ធឿន** , [redacted] **ខ្សៀន** និង [redacted] **ឈូក** ហៅ **ជ្រូក** ពុំទាន់មានសកម្មភាព បង្ករបួសស្នាម ដល់អ្នកដទៃ នៅឡើយ គឺគ្រាន់តែកាន់ដាវ ដំបង ដើរតាមផ្លូវប៉ុណ្ណោះ ។

៤- តាមចម្លើយ ឈ្មោះ [redacted] **វណ្ណ** (ឯ. ១/២៣ ) នៅថ្ងៃ ៥/៩/២០០៥ កូនខ្លួន ដូចមានឈ្មោ ខាងលើនាំគ្នាកាន់ដាវ ដំបង ទៅតាមវាយពួកបងធំ នៅរោងចក្រស្បែកជើង ពីព្រោះពួកវាបានដេញវាយពួកខ្លួ ដល់ផ្ទះ ។

៥- តាមចម្លើយរបស់ឈ្មោះ [redacted] **ឈូក** (ឯ. ១/២១ ) ថា ឈ្មោះ [redacted] **ខ្សៀន** , [redacted] **ចាន់ធឿន** សុទ្ធ កាន់អាវុធគ្រប់ដៃ ដើម្បីទៅសងសឹកពួកបងធំ នៅរោងចក្រស្បែកជើង ព្រោះពួកនោះ ធ្លាប់ដេញវាយពួកខ្លួន ដល់ផ្ទ ។ គឺជាការចេញដំណើរដោយមានអាវុធគ្រប់ដៃ ដើម្បីទៅកាប់សម្លាប់ក្រុមមួយ នៅរោងចក្រស្បែកជើង តែអា ខានទៅវិញ ដោយនគរបាលល្បាតប៉ុស្តិ៍ ឃាត់ខ្លួននៅពេលនោះ ។

៦- សាលក្រមព្រហ្មទណ្ឌ លេខ ២៤ "យ" ចុះថ្ងៃ ២៥-១០-២០០៦ របស់សាលាដំបូងក្រុងភ្នំពេញ មាន លក្ខណៈត្រឹមត្រូវគួរតម្កល់ទុកជាបានការ ។

**ហេតុដូចនេះ ទីនិច្ឆ័យសេចក្តី**

១- ទទួលបណ្តឹងឧទ្ធរណ៍ លេខ ៩៥២ ចុះថ្ងៃ ៣០-១១-២០០៦ របស់ឈ្មោះ [redacted] **ខ្សៀន** , [redacted] **វណ្ណ** និង [redacted] **ឈូក** ទុកជាត្រឹមត្រូវ តាមទម្រង់ច្បាប់ តែលើកចោលដោយទាស់គតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌ លេខ ២៤ "យ" ចុះថ្ងៃ ២៥-១០-២០០៦ របស់សាលាដំបូង ក្រុងភ្នំពេញ ទុកជាបានការ ។

៣- អោយបន្តឃុំខ្លួនជនជាប់ចោទ តាមមាត្រា ៣៩៣ និង ៤០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

១៤៧

៨-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ ។

បើកផ្លូវប្តឹងតវ៉ា តាមកំណត់ច្បាប់ ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ច គ្រប់ថ្នាក់ គ្រប់តំណែង និងកំលាំងប្រដាប់អាវុធ ជួយ សហការ អនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់** ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] [redacted] | ហត្ថលេខា [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ២០១៥
ក្រឡាបញ្ជី

[redacted]

៩៤៣